01486766

លេខ៖ D351/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 06 / 2017
ម៉ោង (Time/Heure): 10:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**
កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧**
ភាសា ៖ **ខ្មែរ/អង់គ្លេស [ភាសាដើម]**
ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំកែប្រែកាលបរិច្ឆេទដាក់ដីកាសន្និដ្ឋានស្ថាពរ

---

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុប្បា
Richard ROGERS
Göran SLUITER

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES NZEPA
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATH

# I. ពិភាក្សា

១. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ យោងតាមវិធានផ្ទៃក្នុង ៦៦(៤) យើងបានបញ្ជូនសំណុំរឿងទៅ សហព្រះរាជអាជ្ញា ដើម្បីពិនិត្យរៀបចំចេញដីកាសន្និដ្ឋានស្ពាពរ[1]។ យោងតាមវិធានផ្ទៃក្នុង ៣៩(៣) និង ៦៦(៥) កាលបរិច្ឆេទកំណត់សម្រាប់ដាក់ដីកាសន្និដ្ឋាននេះ គឺនៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៧ ដោយបានពិគ្រោះយោបល់ជាមួយនឹងផ្នែកសេវាបកប្រែភាសារបស់ អ.វ.ត.ក និង របស់ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម សហព្រះរាជអាជ្ញាអន្តរជាតិ("ស.ព.អ") បានជូនដំណឹងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ថា ការបកប្រែដីកាសន្និដ្ឋានស្ពាពរទាំងស្រុងទៅជាភាសាខ្មែរនឹងត្រូវការរយៈពេលប្រហែលជា ៥ ខែ ហើយនឹងមិនបានចប់រួចរាល់ទេនៅត្រឹមថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧។ អាស្រ័យហេតុនេះ ស.ព.អ បានស្នើសុំ ស.ច.ស កែប្រែកាលបរិច្ឆេទដាក់ដីកាសន្និដ្ឋានស្ពាពរ ហើយបានស្នើសុំជម្រើសចំនួន ៣ ("សំណើ")[2]។

៣. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ មន្ត្រីច្បាប់របស់ ក.ស.ច.ស បានសួរមេធាវីការពារក្តី អោ អាន ថាតើ មេធាវីការពារក្តី មានបំណងឆ្លើយតបទៅនឹងសំណើដែរឬអត់។ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ មេធាវីការពារក្តី អោ អាន បានជូនដំណឹង ក.ស.ច.ស ថា ខ្លួនមិនមានបំណងដាក់សារណាឆ្លើយតបទេ[3]។

៤. ដោយយល់ឃើញថា ផ្នែកសេវាបកប្រែភាសារបស់ អ.វ.ត.ក នឹងត្រូវការពេលវេលាប្រហែលជា ៥ ខែ ដើម្បីបកប្រែដីកាសន្និដ្ឋានស្ពាពរទាំងស្រុងរបស់ ស.ព.អ ទៅជាភាសាខ្មែរ នោះ

---

[1]សំណុំរឿង ០០៤/២ ឯកសារ D351 *ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង* ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧។

[2]សំណុំរឿង ០០៤/២ ឯកសារ D351/1 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំកែប្រែកាលបរិច្ឆេទសម្រាប់ដាក់ដីកាសន្និដ្ឋានស្ពាពរនៃសំណុំរឿង ០០៤/២ ដោយមកពីធនធាននៃការបកប្រែភាសាមានកម្រិត* ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៧។

[3]សំណុំរឿង ០០៤/២ ឯកសារ D351/2.1 *អ៊ីមែលឆ្លើយឆ្លងគ្នារវាង ក.ស.ច.ស ជាមួយនឹងមេធាវីការពារក្តី អោ អាន* ថ្ងៃទី ៣០ និង ៣១ ខែឧសភា ឆ្នាំ ២០១៧។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

ទើប យើងជឿថា ជាលក្ខណៈសត្យានុម័ត ស.ព.អ មិនអាចដាក់សំណៅបកប្រែជាភាសាខ្មែរបានទេនៅត្រឹមថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧។

៥. អាស្រ័យហេតុនេះ យើងអនុញ្ញាតតាមសំណើ ហើយអនុញ្ញាតឱ្យ ស.ព.អ អនុវត្តតាមជម្រើសទី ៣ ដូចដែលបានស្នើសុំ[4]។

**តាមសំអាងហេតុខាងលើ យើង**[5]៖

៦. **អនុញ្ញាតឱ្យ** ស.ព.អ ដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនជាភាសាអង់គ្លេស និងភាសាខ្មែរ នៅត្រឹមថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ដោយឯកសារយោងទុកនៅជាភាសាអង់គ្លេសសម្រាប់សំណៅទាំងពីរភាសា ហើយត្រូវដាក់សំណៅបកប្រែទាំងស្រុងជាភាសាខ្មែរឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅក្រោយកាលបរិច្ឆេទនេះ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges
Co-juges d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម** Michael BOHLANDER

[4]*សូមមើល* សំណើ កថាខណ្ឌ ៣ (iii)។

[5] ខណៈដែលសហចៅក្រមស៊ើបអង្កេតទាំងពីរ បានចេញដីកានេះរួមគ្នា សហចៅក្រមស៊ើបអង្កេតជាតិ កត់សម្គាល់ទុកជាឯកសារថា ឯកសារទាំងឡាយនៃសំណុំរឿង០០៤ ត្រូវចុះលេខរៀងបន្តពីលេខ ឯកសារចុងក្រោយមុនពេលការលាលែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk ដោយមិនរាប់បញ្ចូលឯកសារទាំងអស់ ដែលត្រូវបាន ចេញដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet។